សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

មហាវិទ្យាល័យអប់រំ


កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន កម្រិតបរិញ្ញាបត្រ



# មុខវិជ្ជា៖
# ការអប់រំអំពីបម្រែបម្រួលអាកាសធាតុនៅមធ្យមសិក្សា

កញ្ចប់សមត្ថភាពទី១ ចំណេះដឹងឯកទេសបរិញ្ញាបត្រ



# មុខវិជ្ជា៖
# ការអប់រំអំពីបម្រែបម្រួលអាកាសធាតុនៅមធ្យមសិក្សា

## កញ្ចប់សមត្ថភាពទី ១
## ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ

## ការពណ៌នាអំពីមុខវិជ្ជា

មុខវិជ្ជា៖ការអប់រំអំពីបម្រែបម្រួលអាកាសធាតុនៅមធ្យមសិក្សាផ្ដោតលើការប្រែប្រួលអាកាសធាតុនៅតាមសាលារៀន ដែលមានគោលបំណងបណ្ដុះបណ្ដាលឱ្យអ្នកសិក្សាមានសមត្ថភាពដូចជា៖ យល់ដឹងពីបញ្ញត្តិនៃការអប់រំការប្រែប្រួលអាកាសធាតុនៅតាមសាលារៀននៅមធ្យមសិក្សា ផ្ដល់ការសិក្សាបែបអនុវត្តគម្រោង គោលការណ៍អប់រំការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងគរុកោសល្យការរៀននិងបង្រៀនបែបនវានុវត្តន៍ ហើយមុខវិជ្ជានេះអាចប្រើប្រាស់ចំណេះដឹង និងធនធានដែលមានស្រាប់នៅតាមសាលារៀនដើម្បីដោះស្រាយវិបត្តិការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា។

## លទ្ធផលសិក្សារំពឹងទុក៖

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

លទ្ធផលសិក្សារំពឹងទុកទី ១៖ បង្ហាញការយល់ដឹងអំពីបំណិនការគ្រប់គ្រងបម្រែបម្រួលអាកាសធាតុកំពុងកើតឡើងនៅតាមសាលារៀននៃប្រទេសកម្ពុជា

លទ្ធផលសិក្សារំពឹងទុកទី ២៖ពន្យល់អំពីគោលគំនិតនិងគន្លឹះអនុវត្តន៍នៃការអប់រំពីបម្រែបម្រួលអាកាសធាតុនៅសាលារៀនមធ្យមសិក្សានៅក្នុងបរិបទផ្សេងៗគ្នា

លទ្ធផលសិក្សារំពឹងទុកទី ៣៖ អនុវត្តកិច្ចការនៃការគ្រប់គ្រងនិងកាត់បន្ថយការប្រែប្រួលអាកាសធាតុតាមសាលារៀនមធ្យមសិក្សាឈានឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព

លទ្ធផលសិក្សារំពឹងទុកទី ៤៖ អនុវត្តបំណិនកែច្នៃធនធានដែលមានស្រាប់នៅក្នុងសាលារៀននិងសហគមន៍ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

លទ្ធផលសិក្សារំពឹងទុកទី ៥៖អភិវឌ្ឍផ្នត់គំនិតច្នៃប្រឌិតក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធារតុ

## វាយតម្លៃសិក្សា

*ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ*

១. វត្តមានចូលសិក្សា ១០%

២. ការចូលរួមសកម្មភាពសិក្សា ២០%

៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%

៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

**កិច្ចការត្រូវអនុវត្តដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

កិច្ចការទី ១៖ការអនុវត្តតេស្តខ្លីតាមរយៈGoogle Form

កិច្ចការទី ២៖ សកម្មភាពក្នុងថ្នាក់រៀន ចូលរួមចែករំលែក សំណួរ ចម្លើយ

កិច្ចការទី ៣៖ វត្តមានសិក្សា

កិច្ចការទី ៤៖កិច្ចការស្នូល

កិច្ចការទី ៥៖ប្រឡងបញ្ចប់ការសិក្សាសម្រាប់មុខវិជ្ជានេះ

# អារម្ភកថា

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងចំណុចចតុកោណទី១ បានកំណត់យក "ការអភិវឌ្ឍធនធានមនុស្ស" មុំទី១ជាវិស័យអាទិភាព។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញដើរតួនាទីយ៉ាងសំខាន់ជាចំណែកមួយនៃការកែទម្រង់វិស័យអប់រំក្នុងការស្តារប្រព័ន្ធអប់រំជាតិឡើងវិញ តាមរយៈការផលិតអ្នកអប់រំដែលមានគុណភាពខ្ពស់។

នៅដើមអាណត្តិទី៦នេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់ វិស័យអប់រំ ២០១៨-២០២៣ ដែលមានចក្ខុវិស័យ "កសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន"។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក៏បានលើកឡើងពីតួនាទីយ៉ាងសំខាន់របស់គ្រូបង្រៀនក្នុងវិស័យអប់រំ និងសង្គមជាតិ ដោយបញ្ជាក់ថា "គុណភាពគ្រូ ជាគុណភាពមូលធនមនុស្ស សម្រាប់ ការអភិវឌ្ឍប្រកបដោយចីរភាព" ដែលប្រែក្លាយប្រទេសមានប្រាក់ចំណូល មធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍន៍ក្នុងឆ្នាំ២០៥០។

ដើម្បីឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រ និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានទទួលភារកិច្ចបន្ថែមទៀត តាមរយៈការអនុវត្តគម្រោងកែលម្អការអប់រំនៅកម្រិតមធ្យមសិក្សា និងបន្តអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅរយៈពេលបួនឆ្នាំបន្តទៀត ចាប់ពីឆ្នាំ២០២២-២០២៦។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាបានដឹកនាំ និងផ្តល់អនុសាសន៍យ៉ាងច្រើន ដែលធ្វើឱ្យគម្រោងប្រព្រឹត្តទៅដោយរលូន និង ជោគជ័យ។

គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សារៀបចំឡើង ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូឯកទេសលើមុខវិជ្ជាគោល៦ តាមគ្រឹះស្ថានមធ្យមសិក្សាគោលដៅ។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញទទួលបណ្តុះបណ្តាលក្របខណ្ឌកម្មវិធីកម្រិតបរិញ្ញាបត្រអប់រំដល់នាយកសាលារៀន និងគ្រូឯកទេសដែលពុំទាន់មានសញ្ញាបត្របរិញ្ញាបត្រ ឬមានសញ្ញាបត្រខុសឯកទេសនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំនួន១០០ នៅក្នុងគោលដៅគម្រោងនៅប្រទេសកម្ពុជា។ ដើម្បីពង្រីកវិសាលភាពនៃកំណែទម្រង់អប់រំ គម្រោងកែលម្អការអប់រំចំណេះទូទៅ ដែលប្រើប្រាស់យុទ្ធសាស្ត្រសហគមន៍សាលារៀនជាយុទ្ធសាស្ត្រស្នូលក្នុងការអនុវត្ត បានលេចរូបរាងឡើងក្នុងគោលបំណងបណ្តុះបណ្តាលនាយកសាលា និងគ្រូបង្រៀនចំនួនប្រមាណ ១៧០០០ នាក់ ដែលមកពី ១៧០០សាលា ក្នុងអនុវិស័យបី រួមមាន កុមារតូច បឋមសិក្សា និងមធ្យមសិក្សា។ មហាវិទ្យាល័យអប់រំក៏ត្រូវសហការផងដែរ ជាមួយស្ថាប័ន បណ្តុះបណ្តាលគ្រូទាំងអស់ ដើម្បីឈានទៅបង្កើតស្តង់ដាគុណភាពរួមមួយក្នុងការអប់រំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាឱ្យបានទូលំទូលាយ។ ដើម្បីឈានទៅសម្រេចបានការអនុវត្តគម្រោងថ្មីនេះ មហាវិទ្យាល័យត្រូវមានយុទ្ធសាស្ត្ររយៈពេលវែងមួយ សម្រាប់ឆ្នាំ ២០២១-២០៣០ ដើម្បីជាមគ្គុទេសបង្ហាញផ្លូវ។

សៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀននេះ បានរៀបចំឡើងជាការឆ្លើយតបជាមួយតម្រូវការដែលអ្នកសិក្សាជានាយក និងគ្រូបង្រៀនក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅដើម្បីធ្វើការស្វ័យសិក្សាលើខ្លឹមសារសំខាន់ៗ នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន ដែលការស្វ័យសិក្សានេះបានភ្ជាប់មកជាមួយសំណួរស្វ័យសិក្សា ដែល

បញ្ជាក់ពីកម្រិតយល់ដឹងពីខ្លឹមសារគោលនីមួយៗនៃយុទ្ធសាស្ត្រសហគមន៍សាលារៀន។ តាមរយៈសៀវភៅសិក្សាគោលនេះ អ្នកសិក្សាក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) និងគ្រឹះស្ថានបណ្ដុះបណ្ដាលឯទៀតអាចយកជាប្រយោជន៍ក្នុងការអនុវត្តកំណែទម្រង់សាលារៀន ដែលយកសហគមន៍ជាធនធានគោល ដើម្បីអភិវឌ្ឍន៍សាលារៀនឱ្យឈានទៅរកសាលារៀនជាប់ស្ដង់ដាសហគមន៍សាលារៀន។

ទន្ទឹមនឹងនេះ វាជាឯកសារដែលឆ្លុះបញ្ចាំងពីមេរៀន បទពិសោធន៍នៃការអនុវត្ត និងផលសម្រេចជាក់ស្ដែង និងជាឯកសាររស់ដែលមានលក្ខណៈបើកទូលាយឱ្យមានការកែលម្អបន្តផ្អែកលើការរៀនពីការអនុវត្ត ដែលនាំមកនូវលទ្ធផលវិជ្ជមាន។ ឯកសារនេះមានខ្លឹមសារ ដែលជាអត្ថប្រយោជន៍សម្រាប់ប្រើប្រាស់ក្នុងពេល ដែលបានអនុវត្តន៍កន្លងមក និងបន្តប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន ហើយអាចនឹងប្រើប្រាស់សម្រាប់អនាគត ឬអាចនឹងកែសម្រួលបន្ថែមឱ្យសមស្របតាមកាលៈទេសៈ និងល្បឿននៃការអភិវឌ្ឍក្នុងសង្គមជាតិ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានជំនឿយ៉ាងមុតមាំ ក្នុងការរៀបចំក្របខណ្ឌកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ក្រោមគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាពិតជាដើរតួនាទីយ៉ាងសំខាន់ និងឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការសាងធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងក្រមសីលធម៌។ យើងនឹងបន្តការខិតខំប្រឹងប្រែងក្នុងការអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ឱ្យបានកាន់តែប្រសើរជាមួយនឹងសៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀន និងឧត្តមានុវត្តន៍ផ្សេងៗដែលបានចងក្រង។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរចំពោះក្រុមការងារដែលបានខិតខំកសាងក្របខណ្ឌកម្មវិធីឱ្យទទួលបានលទ្ធផលល្អ។

ថ្ងៃ ពុធ ១៤ រោច ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែ កក្កដា ឆ្នាំ២០២២

**សាកលវិទ្យាធិការ**

**បណ្ឌិត ជេត ជាលី**

## រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រអប់រំមានចំនួន ៦៣ ក្រេឌីត ដោយបញ្ចូលការសិក្សាលើមុខវិជ្ជាសិក្សា ការចូលរួមវគ្គសិក្ខាសាលាជាបន្តបន្ទាប់ ការអនុវត្តផ្ទាល់ និងការចងក្រងរបាយការណ៍ស្រាវជ្រាវ។ ដោយសារអ្នកសិក្សាក្នុង កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនបានបំពេញគុណវុឌ្ឍិចំនួន ៦៣ ក្រេឌីត។ (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងវិធីសាស្រ្តដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន (១២ (+៣) ក្រេឌីត) (៣)ហ្វឹកហាត់កម្មសិក្សា និងការអនុវត្តជាក់ស្តែង (១២ ក្រេឌីត)។

ការចូលរួមសិក្ខាសាលាតម្រូវឱ្យនិស្សិត/អ្នកសិក្សារៀនបន្ថែម និងចែករំលែកបទពិសោធអំពីការអនុវត្តការងារនៅសាលារៀន។ ការអនុវត្តផ្ទាល់ គឺភ្ជាប់និស្សិត/អ្នកសិក្សាទៅនឹងការបំពេញកិច្ចការអនុវត្ត ដើម្បីចងក្រងបទពិសោធនៃការបំពេញការងារផ្អែកលើលទ្ធផល។ របាយការណ៍ស្រាវជ្រាវតម្រូវឱ្យនិស្សិត/អ្នកសិក្សាចងក្រងនូវបទពិសោធដែលអនុវត្តការងារប្រកបដោយផលសម្រេច។

| កញ្ចប់សមត្ថភាព | ចំនួនមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ១២ មុខវិជ្ជា | ៣៦ |
| (២)ចំណេះដឹងវិធីសាស្រ្តដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន (២០%) | ៤(+១) មុខវិជ្ជា | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សានិងការអនុវត្តជាក់ស្តែង (២០%) | ៣ មុខវិជ្ជា | ១២ |
| សរុប | ២០ | ៦៣ |

## ក្របខណ្ឌកម្មវិធីសិក្សាបរិញ្ញាបត្រអប់រំ

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យនិស្សិត/អ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោមដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យនិស្សិត/អ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| កញ្ចប់សមត្ថភាព | មុខវិជ្ជាសិក្សា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេស កម្រិតបរិញ្ញាបត្រ ៣៦ ក្រេឌីត(៦០%) | ចិត្តវិទ្យាអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះអប់រំ | ៣ |
| | ការប្រើប្រាស់កុំព្យូទ័រ និងបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ | ៣ |
| | ភាសាអង់គ្លេសសម្រាប់ការអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃវង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះការស្រាវជ្រាវប្រតិបត្តិ | ៣ |
| | វិធីសាស្រ្តស្រាវជ្រាវ | ៣ |
| | ការគ្រប់គ្រងការរៀន និងបង្រៀន | ៣ |

| | | |
|---|---|---|
| | ភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសាលារៀននិងរដ្ឋបាលសាលារៀន | ៣ |
| | ការសិក្សាពហុវិន័យនៅមធ្យមសិក្សា | ៣ |
| | ការអប់រំអំពីបម្រែបម្រួលអាកាសធាតុនៅមធ្យមសិក្សា | ៣ |
| | បញ្ញាតិ និងគោលការណ៍ការអនុវត្តការគ្រប់គ្រងតាមសាលារៀន | ៣ |
| (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន ១២ (+៣) ក្រេឌីត (២០%) | ការគ្រប់គ្រង និងការវិភាគទិន្នន័យអប់រំ | ៣ |
| | ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអប់រំ | ៣ |
| | ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ | ៣ |
| | ដំណើរការ ការគ្រប់គ្រងសាលារៀននៅមធ្យមសិក្សា | ៣ |
| | ការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនសម្រាប់មធ្យមសិក្សា | ៣ |
| (៣)ហ្វឹកហាត់កម្មសិក្សា និងការអនុវត្តជាក់ស្តែង ១២ ក្រេឌីត (២០%) | ការពិនិត្យតាមដាន និងការវាយតម្លៃគ្រឹះស្ថានសិក្សា | ៣ |
| | ការធ្វើអធិការផ្ទៃក្នុងតាមសាលារៀន | ៣ |
| | ការសរសេររបាយការណ៍ស្រាវជ្រាវ | ៦ |
| សរុប | | ៦៣ |

## លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**



## ស្តង់ដាស្តង់ដាគណៈគ្រប់គ្រងសាលារៀននៃយុទ្ធសាស្ត្រសហគមន៍សាលារៀន

**ស្តង់ដាទី១ និង ៤** សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សារបស់សិស្ស និងដំណើរការរដ្ឋបាល និងប្រតិបត្តិការសហគមន៍សាលារៀន។ក្នុងការបណ្តុះបណ្តាលលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀនទាំងអស់ត្រូវបានណែនាំឱ្យអនុវត្តកិច្ចការដូចតទៅ៖

| | |
|---|---|
| ១ | កែលម្អការសិក្សារៀនសូត្ររបស់សិស្សពីថ្នាក់ទី៧ ដល់ទី១២ នាំឱ្យសិស្សអាចទទួលបានកម្រិតល្អ និងល្អប្រសើរលើមុខវិជ្ជាគោល។ |
| ២ | ផ្តោតការសិក្សារបស់សិស្សលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាជាអទិភាព ពិសេសនៅមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។ |
| ៣ | អនុវត្តអនុសាសន៍របាយការណ៍ការគ្រប់គ្រងហិរញ្ញវត្ថុ និងសវនកម្ម។ |
| ៤ | ធ្វើឱ្យការសិក្សាមានភាពបន្សុីគ្នារវាងសាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាដើម្បីឈានឆ្ពោះទៅឧត្តមសិក្សា។ |
| ៥ | បង្កើនប្រសិទ្ធផល និងកំណត់មុខសញ្ញាប្រើប្រាស់ធនធាន ដោយផ្តោតលើអទិភាពរបស់សាលារៀន ដែលមានមូលដ្ឋានលើយុទ្ធសាស្ត្រ វប្បធម៌ និងគុណតម្លៃ។ |

## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេររបាយការណ៍ស្រាវជ្រាវ និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

## គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាមានដូចតទៅ៖

១) និស្សិត/អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ។

២) ក្នុងករណីដែលនិស្សិត/អ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ។

៣) និស្សិត/អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់។

៤) និស្សិត/អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា។

៥) និស្សិត/អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្នូលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្ដោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍។

៦) និស្សិត/អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពាររបាយការណ៍ស្រាវជ្រាវ។

## ការផ្ដល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

និស្សិត/អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពាររបាយការណ៍។ ពិន្ទុដែលជាប់ត្រូវចាប់ផ្ដើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average – GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point – P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value – C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា "ពិន្ទុជានិទ្ទេស" និង "ពិន្ទុជាតម្លៃលេខ" ដូចដែលពិពណ៌នាដូចខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្ដល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្ដិសិទ្ធ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោមៈ

**ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា**

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្ត ភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងសាលារៀន និងក្រៅសាលារៀន។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិតម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់និស្សិត/អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ការក្លែងបន្លំឯកសារ**

និស្សិត/អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ និស្សិតត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់និស្សិតដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ និស្សិត/អ្នកសិក្សានឹងត្រូវធ្លាក់ជាស្ថាពរ បើនិស្សិត/អ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីនិស្សិតដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

**របាយការណ៍/កិច្ចការស្រាវជ្រាវ**

និស្សិត/អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួនចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិតជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ និស្សិត/អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សា បច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយទេ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សំគាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងដើម្បីឆ្លើយតបវឌ្ឍនភាពការរៀននិងបង្រៀន សមត្ថភាពរៀន និងអនុវត្តជាក់ស្តែង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោង GEIP។

# សេចក្តីផ្តើមការអប់រំការប្រែប្រួលអាកាសធាតុនៅមធ្យមសិក្សា



មហាវិទ្យាល័យអប់រំ

## អំពីខ្ញុំ



**បទពិសោធការងារ**

- គ្រូបង្រៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មហាវិទ្យាល័យអប់រំ សភភព
- អ្នកសម្របសម្រួលកម្មវិធីលើកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀននិងគ្រូបង្រៀនអនុវិស័យទាំងបី
- អ្នកសម្របសម្រួលនិងស្រាវជ្រាវក្នុងគម្រោង ឌីវីអីអន្តរជាតិ ប្រចាំនៅប្រទេសកម្ពុជា SEAMEO និង JICA

**បទពិសោធការសិក្សា**

- កំពុងសិក្សាថ្នាក់បណ្ឌិតអប់រំ មហាវិទ្យាល័យអប់រំ សភភព
- បញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ សាកលវិទ្យាល័យជុឡាឡុងកន ប្រទេសថៃ
- បញ្ចប់ថ្នាក់បរិញ្ញាបត្រអប់រំជំនាញការបង្រៀនភាសាអង់គ្លេស វិទ្យាស្ថានភាសាបរទេស សភភព
- បញ្ចប់ថ្នាក់បរិញ្ញាបត្រអប់រំជំនាញសេដ្ឋកិច្ចអន្តរជាតិ វិទ្យាស្ថានភាសាបរទេស សភភព
- ធ្លាប់បានឆ្លងកាត់ការផ្លាស់ប្តូរការសិក្សាតាមបណ្តាប្រទេសជា៖ សង្ហបុរី ម៉ាឡេស៊ី ឥណ្ឌូនេស៊ី

វៀតណាម ថៃ ឡាវ ហុងកុង ជប៉ុន និងកូរ៉េខាងត្បូង។

# សូមលោកគ្រូ អ្នកគ្រូធ្វើការណែនាំខ្លួន

សូមសេរសេរតាមរយៈតំណនេះ៖
https://forms.gle/RU81ZuA9j2d52Bxr7

## តើអ្វីទៅការអប់រំការប្រែប្រួលអាកាសធាតុ?

Climate Change Education

ការអប់រំការប្រែប្រួលអាកាសធាតុជួយមនុស្សឱ្យយល់ និងដោះស្រាយផលប៉ះពាល់នៃវិបត្តិអាកាសធាតុ និងផ្តល់អំណាចឱ្យពួកគេជាមួយនឹងចំណេះដឹង ជំនាញ តម្លៃ និងអាកប្បកិរិយាដែលត្រូវការដើម្បីដើរតួជាភ្នាក់ងារនៃការផ្លាស់ប្តូរ។



## តើអ្វីទៅជាការប្រែប្រួលអាកាសធាតុ

- សូមមើលវីដេអូនេះតាមរយៈតំណនេះ៖ https://youtu.be/bV-fFs_RK9c?si=D56hKq0LOKx8fjUO




## តើហេតុអ្វីភពផែនដីឡើងកម្តៅ?

- តាមរយៈអ្នកវិទ្យាសាស្ត្របានបង្ហាញមនុស្សជាកត្តាចម្បងធ្វើផែនដីឡើងកម្តៅតាមរយៈសកម្មភាពមួយចំនួនដូចជា៖
- ការកាប់បំផ្លាញព្រៃឈើ
- រោងចក្រផលិតសម្ភារៈ
- ការប្រើប្រាស់ឥន្ទនៈផូស៊ីល




## តើការប្រែប្រួលអាកាសធាតុមានឥទ្ធិពលយ៉ាងណាមកលើយើង?

- ភពផែនដីចាប់កើនកម្ដៅ
- គ្រោះធម្មជាតិកាន់តែច្រើន
  - រាំងស្ងួត
  - ទឹកជំនន់
  - ខ្យល់ព្យុះ។ល។

## តើយើងត្រូវធ្វើយ៉ាងណាដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ?

- គិតរបៀបបន្សុំពីការប្រែប្រួលនេះ
- ដាំដើមឈើ
- ការពារព្រៃឈើ
- មានផែនការសាងសង់ការពារបរិស្ថាន
- ជ្រើសរើសពូជដំណាំដែលអាចផ្សាំជាមួយការប្រែប្រួលអាកាសធាតុ






# ភាពខុសគ្នាការអប់រំ និងការរៀន?

- ការអប់រំ (Education)
  - ការកែប្រែ/ការផ្លាស់ប្តូរ (ពលរដ្ឋល្អ) ពលរដ្ឋសកល (Global Citizen)
  - ឥរិយាបថ និងចំណេះដឹង
  - ប្រព័ន្ធ/ផ្លូវការ
  - ផ្តល់សេវា (សាលារៀន សាកលវិទ្យាល័យ វិទ្យាស្ថាន...)
  - បំណិន ចំណេះដឹង ឥរិយាបថ
  - មានអាយុជាក់លាក់
- ការរៀន (Learning)
  - រៀនឱ្យចេះ
  - មិនផ្លូវការ/មិនរចនាសម្ព័ន្ធ
  - អ្នកទទួលសេវា (ខ្លួនឯង)
  - មិនកំណត់អាយុ

# សូមមើលវីដេអូនេះបន្ថែម

https://youtu.be/v9aWEc9eWeg?si=nluJ8Ac9WX_U3PXn






# បញ្ញត្តិនៃការអប់រំការប្រែប្រួលអាកាសធាតុ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

នាក់ ពិសិដ្ឋ






- អប់រំក្នុងប្រព័ន្ធ (Formal Education)៖ រៀនក្នុងសាលារៀន (មត្តេយ្យសិក្សា ដល់ឧត្តមសិក្សា)
- អប់រំក្រៅប្រព័ន្ធ (Non-Formal Education)៖ រៀនបែបសហគមន៍ កន្លែងការងារ (មជ្ឈមណ្ឌលសិក្សាសហគមន៍)
- អប់រំមិនផ្លូវការ (Informal Education)៖ រៀនពីគ្រួសារ បងប្អូន មិត្ត...
- អប់រំពេញមួយជីវិត




## Sustainable Development Goals (SDGs)

- Equity
- Inclusive education

# គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព



# សូមមើលវីដេអូតាមរយៈតំណនេះ៖

https://youtu.be/6Is8GKSHOpo?si=QprcCXFmmbOM5jJC



# ការអប់រំដែលមានចីរភាព

ការអប់រំដែលមានចីរភាព ឬការអប់រំប្រកបដោយចីរភាព និង ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពគឺជាពាក្យតែមួយដែលត្រូវបានគេប្រើផ្លាស់ប្តូរគ្នាទៅវិញទៅមកដើម្បីព័ណ៌នាការអនុវត្តការបង្រៀនឱ្យមាននិរន្តភាព។

ពាក្យនេះត្រូវបានគេប្រើប្រាស់ជាអន្តរជាតិដោយរបៀបវារៈអង្គការសហប្រជាជាតិលើកទី២១ដែលកំណត់យកការអប់រំថាជាឧបករណ៏ដ៏សំខាន់មួយសម្រាប់ធ្វើឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៏ប្រកបដោយនិរន្តភាពតាមរយៈដាក់បញ្ចូលពីសកម្មភាពនានាក្នុងការអប់រំ។

ការអប់រំ គឺជាឧបករណ៍មូលដ្ឋានសម្រាប់ជំរុញសកម្មភាពឈានមុខលើការប្រែប្រួលអាកាសធាតុ ប៉ុន្តែវាមិនទាន់ទាញយកសក្តានុពលបានគ្រប់គ្រាន់នៅឡើយ។



ការស្រាវជ្រាវបានបង្ហាញថា ប្រសិនបើសិស្សវិទ្យាល័យត្រឹមតែ ១៦% នៅក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់ និងមធ្យមទទួលការអប់រំពីការប្រែប្រួលអាកាសធាតុ នោះយើងអាចឃើញការថយចុះយ៉ាងខ្លាំង នៃកាបូនឌីអុកស៊ីតនៅឆ្នាំ២០៥០។

បណ្តាប្រទេសដែលចាត់វិធានការអាកាសធាតុខ្លាំង នៅចន្លោះឆ្នាំ២០១៨ និង២០៣០ ដែលអាចនាំឱ្យនៅឆ្នាំ២០៣០ បង្កើតការងារថ្មីជាង ៦៥លានដែលជាការងារមានកាបូនទាប និងផ្តល់យ៉ាងហោចណាស់ ២៦ពាន់ពាន់លានដុល្លារនៅក្នុងអត្ថប្រយោជន៍សេដ្ឋកិច្ចពិភពលោក, នេះបើយោងតាមគណៈកម្មការសកលស្តីពីសេដ្ឋកិច្ច និងអាកាសធាតុ។

## គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅប្រទេសកម្ពុជា

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពគឺជាការអំពាវនាវឱ្យធ្វើសកម្មភាពជាសាកលដើម្បីបញ្ចប់ភាពក្រីក្រ ការពារបរិស្ថាន និងអាកាសធាតុរបស់ផែនដី ហើយធានាថាមនុស្សនៅគ្រប់ទីកន្លែងអាចទទួលបានសន្តិភាព និងវិបុលភាព។



# វិធី ៤យ៉ាងដែលការអប់រំអាចប្រើប្រាស់ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ






## រំលឹកមេរៀន

- កត្តាធ្វើឱ្យអាកាសធាតុប្រែប្រួល (ប្រេងឥន្ធន ផ្លាស្ទីក ឧស្ម័នផ្ទះកញ្ចក់ ការកាប់បំផ្លាញព្រៃឈើ ...)
- Sustainable Development Goals (2015) SDGs (គោលដៅការអភិវឌ្ឍប្រកបដោយចីរភាព៖ ១៧គោលដៅ) គោលដៅទី៤ ផ្តោលលើការអប់រំ៖ ធានាការអប់រំប្រកបដោយសមធម៌ (Equity) បរិយាបន្ន (Inclusive) និងលើកកម្ពស់ក្នុងការសិក្សាពេញមួយជីវិត (Lifelong Learning) សម្រាប់អ្នកទាំងអស់គ្នា។ សមធម៌ (Equity) និងភាពស្មើគ្នា (Equality)
- ការអប់រំក្រៅប្រព័ន្ធ ក្នុងប្រព័ន្ធ និងមិនផ្លូវការ
- ការអប់រំប្រកបដោយបរិយាបន្ន
- ការអប់រំជាភ្នាក់ងារផ្លាស់ប្តូរក្នុងការប្រែប្រួលអាធាតុ
- ប្រសិទ្ធភាព (Effectiveness)
- សក្តិសិទ្ធភាព/ប្រសិទ្ធផល (Efficiency)
- Economic
- ប្រសិទ្ធផល




# ទី១. ធានាឱ្យបាននូវគោលនយោបាយពង្រឹងគ្នាទៅវិញទៅមកសម្រាប់ការអប់រំ និងការប្រែប្រួលអាកាសធាតុ

- នៅក្នុងការស្ទង់មតិសកលដោយអង្គការយូណេស្កូក្នុងឆ្នាំ២០២០ អ្នកឆ្លើយសំណួរជិត ២ភាគ៣ បានចាត់ទុកការប្រែប្រួលអាកាសធាតុ និងការបាត់បង់ជីវៈចម្រុះថាជាបញ្ហាប្រឈមលេខមួយ ហើយការអប់រំជាគន្លឹះក្នុងការដោះស្រាយបញ្ហា។
- របាយការណ៍បង្ហាញថា ជាងពាក់កណ្តាលនៃគោលនយោបាយអប់រំ និងកម្មវិធីសិក្សាដែលបានសិក្សាមិនបាននិយាយអំពីការប្រែប្រួលអាកាសធាតុនៅក្នុងការអប់រំបឋមសិក្សា និងមធ្យមសិក្សានោះទេ។
- ជាមួយគ្នានេះ ការអប់រំសម្រាប់បម្រែបម្រួលអាកាសធាតុចាំបាច់ត្រូវបញ្ចូលក្នុងការអប់រំគ្រប់កម្រិត និងនៅក្នុងស្ថាប័នផ្លូវការ សហគមន៍ និងកន្លែងធ្វើការ។
- សាលារៀនអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនការយល់ដឹងរបស់សហគមន៍មូលដ្ឋានអំពីបញ្ហាហានិភ័យអាកាសធាតុ និងគ្រោះមហន្តរាយ និងលើកកម្ពស់សកម្មភាពក្នុងតំបន់ដើម្បីកសាងភាពធន់ (Resilience)។

# ទី២. កសាងជំនាញបៃតងក្នុងកម្លាំងពលកម្ម

ការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍ជំនាញ គឺមានសារៈសំខាន់សម្រាប់ការផ្លាស់ប្តូរដ៏ត្រឹមត្រូវនិងបៃតង និងការកសាងសេដ្ឋកិច្ចដែលធន់ ជាពិសេសឥឡូវនេះជាមួយនឹងសេដ្ឋកិច្ចក្រោយកូវីដ-១៩ បានលើកកម្ពស់ការងើបឡើងវិញនៃពណ៌បៃតង។

ការអប់រំថ្នាក់ឧត្តមសិក្សា និងការស្រាវជ្រាវ ដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងធនធានមនុស្សដែលមានសណ្តាប់ធ្នាប់ខ្ពស់សម្រាប់ភាពធន់ និងសកម្មភាពអាកាសធាតុ។

កិច្ចព្រមព្រៀងបៃតងអ៊ឺរ៉ុប និងកិច្ចព្រមព្រៀងបៃតងរបស់សាធារណរដ្ឋកូរ៉េ គឺជាឧទាហរណ៍ដែលទាមទារធនធានមនុស្សយ៉ាងទូលំទូលាយ។

## ទី៣. ពង្រីកការវិនិយោគនៅចំនុចប្រសព្វនៃនិរន្តរភាព និងឌីជីថលនីយកម្ម

ការបំប្លែងឌីជីថលដែលកំពុងដំណើរការនាពេលនេះ គឺឈានដល់កម្រិតឆ្ងាយ ។ ទំហំទីផ្សារនៃឧស្សាហកម្មសំណង់ឌីជីថលសកល ឬសំណង់ ៤.០ ដោយប្រើបញ្ញាសិប្បនិម្មិត (Art Intelligence) និងបច្ចេកវិទ្យាផ្សេងទៀត ត្រូវបានគេព្យាករណ៍ថានឹងកើនឡើងពី ១០ពាន់លានដុល្លារក្នុងឆ្នាំ២០១៧ ដល់២៩ ពាន់លានដុល្លារនៅឆ្នាំ២០២៧ ។

សេវាកម្ម ឬការងារសេដ្ឋកិច្ចធំ ជំនាញឌីជីថលដ៏ធំទូលាយមានតម្រូវការខ្ពស់។

# ទី៤. ពង្រឹងការសិក្សាអាកាសធាតុអន្តរវិន័យ

- Chat-GPT
- មានតម្រូវការសម្រាប់ការអប់រំអន្តរកម្មសិក្សា។
- ការសិក្សាអំពីអាកាសធាតុនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ត្រូវរួមគ្នាបង្កើតសាលាផ្សេងៗគ្នាដូចជា វិស្វកម្ម ស្ថាបត្យកម្ម កសិកម្ម សិល្បៈ វិទ្យាសាស្ត្រសង្គម ការគ្រប់គ្រង ច្បាប់ គោលនយោបាយសាធារណៈ និងទំនាក់ទំនង ដើម្បីបង្កើតក្រុមទេពកោសល្យចម្រុះដែលត្រូវការសម្រាប់ដំណោះស្រាយអាកាសធាតុ។
- ការអប់រំត្រូវការភ្ជាប់ទំនាក់ទំនងជាមួយតួអង្គផ្សេងទៀតជាច្រើន ដើម្បីសម្រេចបាននូវគោលដៅអាកាសធាតុ ប៉ុន្តែវាត្រូវតែជាអាទិភាព។

ក្នុងបរិបទកម្ពុជា ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក៏បានរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ មានគោលដៅជំរុញសេដ្ឋកិច្ចជាតិឱ្យមានកំណើនថេរ កាត់បន្ថយនិងទប់ស្កាត់ការបំពុលបរិស្ថាន រក្សាសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី កាត់បន្ថយភាពក្រីក្រ បង្កើនសេវាសុខភាពសាធារណៈនិងគុណភាពអប់រំ គ្រប់គ្រងធនធានធម្មជាតិ ការប្រើប្រាស់ដីធ្លី និងធនធានទឹកប្រកបដោយនិរន្តរភាព បង្កើនប្រសិទ្ធភាពថាមពល ធានាសុវត្ថិភាពចំណីអាហារ និងលើកតម្កើងវប្បធម៌ជាតិ៕

ភាពក្រីក្រមាន៣៖ ក្រីក្រថវិកា (Financial Poverty) ក្រីក្រសង្គម (Social Poverty) ក្រីក្រការរៀនសូត្រ (Learning Poverty)

បឋម (៩៥%) សកល (១០%)

# ផលប៉ះពាល់ពីការប្រែប្រួលធាតុអាកាស

**ការរលាយទឹកកក**





# ផលប៉ះពាល់ពីការប្រែប្រួលធាតុអាកាស

ការរំហួតចំហាយទឹក

# ផលប៉ះពាល់ពីការប្រែប្រួលធាតុអាកាស

## ភាពរាំងស្ងួត



# ផលប៉ះពាល់ពីការប្រែប្រួលធាតុអាកាស

## ការកើនឡើងកម្ពស់ទឹកសមុទ្រ



## ផលប៉ះពាល់ពីការប្រែប្រួលធាតុអាកាស

ភ្លៀងធ្លាក់ខ្លាំងនិងមិនទៀងទាត់



## ផលប៉ះពាល់ពីការប្រែប្រួលធាតុអាកាស

សីតុណ្ហភាពកើនឡើង








## ទីប្រជុំជន និងផ្លូវថ្នល់

- ទឹកជំនន់លិចប្រព័ន្ធលូ និងផ្លូវថ្នល់
- ទឹកជំនន់លិចស្ពាន
- ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត

# ធនធានទឹក

## ប្រភពទឹករីងស្ងួត

## កង្វះទឹកស្អាតប្រើប្រាស់

## បាត់បង់គុណភាពរបស់ទឹក



# ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត

- ទឹកជំនន់លិចដំណាំ
- ភាពរាំងស្ងួតប៉ះពាល់ដល់ដំណាំ
- ដីបាត់បងដីរជាតិ



# ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ




## អនុវត្តគោលការណ៍ ៣ Rs

- ការកាត់បន្ថយការប្រើប្រាស់ផលិតផលប្លាស្ទិក
- ការប្រើប្រាស់ឡើងវិញ
- ការកែច្នៃឡើងវិញ



# អនុវត្តគោលការណ៍ ៣ Rs

- ការសន្សំសំចៃទឹក
- ការសន្សំសំចៃភ្លើង
- ការកាត់បន្ថយការប្រើប្រាស់ថាមពលអគ្គីសនី
- ការបែងចែកសំរាម



# បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

- កសិកម្ម
- ធនធានទឹក
- ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

## កសិកម្ម

- ការរៀបចំដីឱ្យបានសមស្រប
- ជ្រើសរើសពូជដំណាំស្របនឹងការប្រែប្រួលអាកាសធាតុ
- ការប្រើប្រាស់ប្រព័ន្ធស្រោចស្រពសន្សំសំចៃទឹក
- ប្រើប្រាស់ជីសរីរាង្គ

## ធនធានទឹក

- ស្ពានប្រព័ន្ធប្រឡាយ
- អាងស្តុកទឹក



# ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

## ការសាងសង់ផ្លូវថ្នល់ដែលធន់នឹងការប្រែប្រួលអាកាសធាតុ



ប្រទេសកម្ពុជា សហការជាមួយសហគមន៍អន្តរជាតិដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែលជាសមាជិកនៃអនុញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុហើយជាប្រទេសចូលរួមកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ដែលបណ្តាលមកពីការបាត់បង់ និងរិចរិលព្រៃឈើ។

**ការឆ្លើយតបរបស់រាជរដ្ឋាភិបាលទៅនឹងការប្រែប្រួលអាកាសធាតុ**


ការអប់រំប្រែប្រួលអាកាសធាតុនៅមធ្យមសិក្សា
មហាវិទ្យាល័យអប់រំ


សាលារៀននៅថ្ងៃអនាគត

*បន្តលើកកម្ពស់សុខភាពអនាម័យនៅតាមគ្រឹះស្ថានសិក្សា ត្រៀមវិធានការឆ្លើយតប និងចូលរួមទប់ស្កាត់ភ្លាមៗ និងបង្កើនការអប់រំអំពីសុវត្ថិភាពសុខភាពសិក្សា សុវត្ថិភាពចំណី អាហារ កែលម្អហេដ្ឋារចនាសម្ព័ន្ធសុខភាព ដូចជា៖ រៀបចំបន្ទប់សុខភាពស្តង់ដា បរិស្ថានសាលារៀនបៃតង សាលារៀនស្អាតគ្មានសំរាម និងការលើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យ*

*អនុសាសន៍សម្តេចមហាបវរធិបតី
ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី*



| Indicator Name | PBC | Baseline | Intermediate Targets | | | | End Target |
|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | |
| Percentage of schools receiving coaching support to improve school operations and increase community support (Percentage) | PBC 2 | 0.00 | 20.00 | 40.00 | 60.00 | 70.00 | 80.00 |
| Preprimary school level (Percentage) | | 0.00 | 20.00 | 40.00 | 60.00 | 70.00 | 80.00 |
| Primary school level (Percentage) | | 0.00 | 20.00 | 40.00 | 60.00 | 70.00 | 80.00 |
| Secondary school level (Percentage) | | 0.00 | 20.00 | 40.00 | 60.00 | 70.00 | 80.00 |
| Number of targeted schools that include content on climate change in school curriculum (Number) | | 0.00 | 0.00 | 50.00 | 200.00 | 400.00 | 400.00 |

| | | | | | |
|---|---|---|---|---|---|
| Secondary school level | | | | | |
| Number of targeted schools that include content on climate change in school curriculum | This is a climate change related indicator. The curriculum on climate change will be developed by teacher training institutions to train the teachers and school leaders who come for in-service training. The climate change course contents will be implemented in the targeted schools. | Annually | School effectiveness database | The targeted schools and national core trainers annually report whether the schools have taught their students on the climate change courses in school effectiveness database. | M&E, PED, GSED |





ការអប់រំ គឺជាឧបករណ៍មូលដ្ឋានសម្រាប់ជំរុញសកម្មភាពឈានមុខលើការប្រែប្រួលអាកាសធាតុ ប៉ុន្តែវាមិនទាន់ទាញយកសក្ដានុពលបានគ្រប់គ្រាន់នៅឡើយ។ ការស្រាវជ្រាវបានបង្ហាញថា ប្រសិនបើសិស្សវិទ្យាល័យត្រឹមតែ ១៦% នៅក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់ និងមធ្យមទទួលការអប់រំពីការប្រែប្រួលអាកាសធាតុ នោះយើងអាចឃើញការថយចុះយ៉ាងខ្លាំង នៃកាបូនឌីអុកស៊ីតនៅឆ្នាំ២០៥០។







*សន្និសីទអង្គការសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ នៅទីក្រុងបាលី។ រូបភាព ដោយ អង្គការ អុកស្វាម អន្តរជាតិ, ៤ ធ្នូ ២០០៧។ ក្រោមអាជ្ញាប័ណ្ណ CC BY-NC-ND 2.0*

កម្ពុជាទទួលបានចំណាត់ថ្នាក់ក្នុងចំណោមប្រទេសដែលងាយរងផលប៉ះពាល់ជាងគេ ដោយសារការប្រែប្រួលអាកាសធាតុ ខណៈពេលដែលប្រជាជនមួយភាគធំពឹងអាស្រ័យលើរបរកសិកម្មសម្រាប់ចិញ្ចឹមជីវិត និងកំពុងរស់នៅតំបន់ដែលងាយទទួលរងទឹកជំនន់។ របបទឹកភ្លៀងកំពុងមានការប្រែប្រួល និងរឹតតែមិនអាចព្យាករដឹងមុនបាន ដែលនាំឱ្យមានព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរកាន់តែច្រើនឡើង ដូចជា ព្យុះត្រូពិច គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ជាដើម។

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានសម្រេចជោគជ័យយ៉ាងច្រើនក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ប៉ុន្តែ ការកើនឡើងនូវសម្ពាធមកលើប្រព័ន្ធអេកូឡូស៊ីរបស់កម្ពុជា ដែលមានទំនាក់ទំនងជាមួយនឹងការប្រែប្រួលអាកាសធាតុ និងបញ្ហាបរិស្ថានដ៏ស្មុគស្មាញ រាប់បញ្ចូលទាំងបញ្ហាឆ្លងដែន ដែលមានទំនាក់ទំនងជាមួយនឹងទន្លេមេគង្គផងដែរនោះ គឺជាអ្វីដែលចាំបាច់ត្រូវយកមកធ្វើការពិចារណាក្នុងគំរូនៃការអភិវឌ្ឍរបស់ខ្លួន ហើយប្រសិនបើកម្ពុជាចង់សម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDGs)។

**ភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣** — កម្ពុជាអាចសម្រេចចក្ខុវិស័យអភិវឌ្ឍន៍របស់ខ្លួនបាន ប្រសិនបើប្រទេសនេះធ្វើចំណាត់ការលើបម្រែបម្រួលអាកាសធាតុតាមរយៈសកម្មភាពធំៗបី គឺ ***កាត់បន្ថយ*** ( *Reduce* ) ឱ្យបានច្រើននូវភាពងាយរងគ្រោះដោយសារបម្រែបម្រួលអាកាសធាតុ; ***សម្របឡើងវិញ*** ( *Realign* ) នូវគន្លងបំភាយកាបូននៅក្នុងការអភិវឌ្ឍ; និង ***តម្រង់ទិសឡើងវិញ*** ( *Reorient* ) សម្រាប់សេដ្ឋកិច្ច ដើម្បីក្រសោបយកឱកាសថ្មីៗពីការធ្វើអន្តរកាលទៅរកការអភិវឌ្ឍបៃតងលើសកលលោក។ នេះបើយោងតាមរបាយការណ៍ស្តីពី **ស្ថានភាពអាកាសធាតុនិងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា** ( Country Climate and Development Report/CCDR ) របស់ធនាគារពិភពលោកដែលចេញផ្សាយកាលពីពេលថ្មីៗនេះ។

អង្គការសហប្រជាជាតិនៅកម្ពុជាកំពុងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពទី ១៣ «ដែលផ្តោតលើសកម្មភាពអាកាសធាតុ» និងចាត់វិធានការបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជាផលប៉ះពាល់ដែលបង្កឡើងដោយសារការប្រែប្រួលអាកាសធាតុ។

## *បរិស្ថានសិក្សា*

*-បង្កើតបរិស្ថានសាលារៀនស្អាត*
*-ការលើកកម្ពស់អនាម័យ និងបរិស្ថានបៃតង*
*-ការអនុវត្តសកម្មភាពបន្ថែមទាំងក្នុងថ្នាក់ និងក្រៅថ្នាក់*
*-ការអប់រំសុខភាពសិក្សាដើម្បីបណ្ដុះទម្លាប់ល្អ វិន័យ សីលធម៌ និងឥរិយាបថ*

# *តើលោក លោកស្រីពេញនឹងបរិស្ថានសាលារបស់ខ្លួនហើយឬនៅ ?*

# *សាលារៀនស្អាតក្នុងក្របខណ្ឌយុទ្ធនាការសាលារៀនគ្មានសំរាម*

*ដើម្បីធ្វើឱ្យសាលារៀនគ្មានសំរាម គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អ្នកពាក់ព័ន្ធត្រូវអនុវត្តវិធានការ៤គឺ៖*

-ចក្ខុវិស័យ និងការប្ដេជ្ញាចិត្ត៖ គណៈគ្រប់គ្រង និងបុគ្គលិកត្រូវមានការប្ដេជ្ញាចិត្តខ្ពស់ មានស្មារតីការងារជាក្រុម ភាពជាម្ចាស់ និងចក្ខុវិស័យ ដើម្បីកែលម្អសាលារៀនស្របតាមស្តង់ដាសាលាកុមារមេត្រីបរិស្ថាន និងសូចនាករស្តង់ដាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ

-ការចូលរួម៖ ព្រះសង្ឃ គ្រូបង្រៀន សិស្ស មាតាបិតា សហគមន៍ និងអាជ្ញាធរមូលដ្ឋានត្រូវចូលរួមគាំទ្រក្នុងគ្រប់រូបភាព

*ដើម្បីធ្វើឱ្យសាលារៀនគ្មានសំរាម គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អ្នកពាក់ព័ន្ធត្រូវអនុវត្តវិធានការ៤គឺ៖*

-ភាពជាអ្នកដឹកនាំ៖ សកម្មភាពក្នុងការកៀរគរធនធាន ការបង្កើតជំនឿទុកចិត្ត ការគ្រប់គ្រងប្រកបដោយតម្លាភាព
-ការបង្កើតយន្តការគ្រប់គ្រងៈ ការចូលរួមរបស់ក្រុមប្រឹក្សាកុមារ និងបុគ្គលិកកសាង និងការថែទាំបរិស្ថានសិក្សា

តើសាលារៀនរបស់លោក លោកស្រី បានបែងចែកសិស្ស និងសកម្មភាពនាំសិស្សសម្អាត និងថែទាំថ្នាក់រៀន ទីធ្លាសាលារៀន និងបន្ទប់ទឹក មិនឲ្យមានសម្រាម និងកន្លែងកខ្វក់ដែរឬទេ ?

តើសាលារៀនរបស់លោក លោកស្រី បាន អនុវត្តសកម្មភាពរៀបចំ និងកែលម្អផ្លូវដើរ និងទីធ្លាក្នុងបរិវេណសាលារៀនដែរឬទេ?

តើសាលារៀនរបស់លោក លោកស្រី បានអនុវត្តសកម្មភាពដាំដើមឈើ ដាំដំណាំ ចិញ្ចឹមសត្វ និងរៀបចំសួនច្បារក្នុងសាលារៀន ជាគម្រូ សម្រាប់ឲ្យសិស្សយកទៅអនុវត្តជាក់ស្តែងនៅតាមផ្ទះរៀងៗខ្លួនដែរឬទេ?

តើសាលារៀនរបស់លោក លោកស្រី បានអនុវត្តសកម្មភាពនាំសិស្សដាំដំណាំ និងចិញ្ចឹមសត្វនៅសាលារៀនជាគំរូឧទាហរណ៍ ជាមូលដ្ឋានសម្រាប់សិស្សយកទៅអនុវត្តជាក់ស្តែងនៅសាលារៀនផងនិងនៅតាមផ្ទះផងដែរឬទេ ?



ចំណុចមួយចំនួនដែលសាលាអាចធ្វើបាន៖

# តម្រង់ទិសដល់សិស្សពីបរិស្ថានសាលាបៃតង





# លើកទឹកចិត្តសិស្ស បង្កើតបរិស្ថានដោយខ្លួនឯង (DIY)



# កសាងភូមិ បៃតង



# កូនសិស្សចង់ ក្រងការណីសិក្សា

*សូមលោក លោកស្រី
បំពេញកម្រងសំណួរ
តាមរយៈតំណនេះ៖
https://forms.gle/hG7iHyxgvQBfW1859*




"The illiterate of the 21st century will not be those who cannot read and write, but those who cannot learn, unlearn, and relearn"
Alvin Toffler


សូមអរគុណ!